# ការអនុវត្តប្រព័ន្ធច្បាប់ផ្សេងគ្នានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងក្លាយជាឧបសគ្គសម្រាប់ភាគីឬ?

*ថ្ងៃទី២៣ ខែវិច្ឆកា ឆ្នាំ២០១២*

*លឹម ជ័យទ័ត្ត, អ្នកសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម*

*មជ្ឈមណ្ឌលឯកសារកម្ពុជា*

*នៅថ្ងៃទី២២ ខែវិច្ឆកា ឆ្នាំ២០១២ នៅអំឡុងពេលនៃសវនាការស្ដីពីការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មាស សារាន មេធាវីអន្តរជាតិការពារក្ដីឲ្យជនជាប់ចោទ នួន ជា គឺលោក អេនឌ្រូ អ៊ីនូហ៊្វី បានសាកសួរសំណួរជាច្រើនទាក់ទងនឹងប្រវត្តិសាវតារ និងស្ថានភាពនៃទីក្រុងភ្នំពេញនៅមុនពេលនៃការជម្លៀសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ មេធាវី អ៊ីនូហ៊្វី បានប្រើប្រាស់វិធីសាស្ត្រនៃការសួរសំណួររបស់ខ្លួនចំពោះដើមបណ្ដឹងរដ្ឋប្បវេណី មាស សារាន ដោយចាប់ផ្ដើមជាមួយនឹងពាក្យថា "តើត្រឹមត្រូវទេ?" ឬ "តើលោកយល់ស្របជាមួយខ្ញុំទេ?" ជាច្រើនដង ។ ឧទាហរណ៍ មេធាវី អ៊ីនូហ៊្វី បានចោទសួរដើមបណ្ដឹងរដ្ឋប្បវេណីថា "តើលោកយល់ស្របជាមួយខ្ញុំទេ ដែលថាប្រជាជននៅទីក្រុងនៅខែមេសា ឆ្នាំ១៩៧៥ មានការកើនឡើងចំនួនទ្វេរដង?" និងឧទាហរណ៍មួយផ្សេងទៀត "តើត្រឹមត្រូវដែរទេ? ដែលថានៅមុនពេលលោកចេញទៅស៊ីសុផុននៅឆ្នាំ១៩៧៣ នៅទីក្រុងកំពុងប្រឈមមុខនឹងការព្យាបាលជំងឺដោយសារការផ្គត់ផ្គង់ថ្នាំពេទ្យ និងឧបករណ៍ផ្សេងៗកំពុងមានបញ្ហា? "។ ការសួរសំណួរដូច្នេះ បានទទួលរងការជំទាស់ពីសំណាក់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វាំងសង់ ដឺវាល់ ដេស្មាឯល ។ តំណាងសហព្រះរាជអាជ្ញាបានអះអាងថា វិធីសាស្ត្រក្នុងការសួរសំណួររបស់មេធាវីការពារក្ដី នួន ជា ចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ដោយផ្ដើមជាមួយនឹងពាក្យថា "តើត្រឹមត្រូវទេ?"ជាច្រើនដង គឺជាការសួរសំណួរដែលមានលក្ខណៈនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីឲ្យឆ្លើយយល់ស្របតាមខ្លួន ហើយតំណាងសហព្រះរាជអាជ្ញា វាំងសង់ ក៏បានស្នើសុំឲ្យក្រុមមេធាវីការពារក្ដី នួន ជា រៀបចំសំណួររបស់ខ្លួនឡើងវិញ ។ ឆ្លើយតបនឹងការជំទាស់របស់តំណាងសហព្រះរាជអាជ្ញា មេធាវី អ៊ីនូហ៊្វី បានបញ្ជាក់ថា ការសួរសំណួរដូច្នេះ ដោយសារខ្លួនយល់ថា ដើមបណ្ដឹងរដ្ឋប្បវេណីគឺជាបុគ្គលដែលមានចំណេះដឹង និងមានសមត្ថភាពអាចឆ្លើយតបនឹងសំណួរដែលខ្លួនចោទសួរបាន ។*

*បន្ទាប់ពីបានពិភាក្សាក្នុងចំណោមចៅក្រមអង្គជំនុំជម្រះ ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានសម្រេចថា ការកត់សម្គាល់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិចំពោះវិធីសាស្ត្រក្នុងការចោទសួររបស់មេធាវីការពារក្ដី គឺមានភាពសមស្រប និងបង្គាប់ឲ្យមេធាវីការពារក្ដី នួន ជា រៀបចំវិធីសាស្ត្រក្នុងការសួរសំណួររបស់ខ្លួនឡើងវិញ ។ ចៅក្រម និល ណុន បានសង្កត់ធ្ងន់ថា សំណួរនាំមុខ ឬសំណួរ*

ដែលធ្វើឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សី ឆ្លើយបញ្ជាក់លើសេចក្ដីសន្និដ្ឋានរបស់ភាគី គឺជាការមិនត្រឹមត្រូវ ។ ឆ្លើយតបនឹងការសម្រេចរបស់អង្គជំនុំជម្រះ មេធាវី អ៊ីនូហ្វ៊ី បានអះអាងថា ការសួរសំណួរឲ្យសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការបញ្ជាក់ គឺជាភាពចាំបាច់មួយ ដែលត្រូវបានអនុវត្តជាទូទៅនៅក្នុងប្រព័ន្ធច្បាប់សាមញ្ញ (Common Law) និងថាសំណុំរឿង០០២ គឺជាសំណុំរឿងដែលមានទំហំធំ ហេតុនេះមេធាវីការពារក្ដីមានការលំបាកក្នុងការសួរសំណួរដែលមានលក្ខណៈបើក ។ ប៉ុន្ដែ ប្រធានអង្គជំនុំជម្រះបានពន្យល់មេធាវី អ៊ីនូហ្វ៊ី វិញថា នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ប្រភពច្បាប់ដែលត្រូវបានយកមកអនុវត្ត គឺយកចេញពីប្រព័ន្ធច្បាប់ប្បវេណី (Civil Law) ហើយសំណួរដែលមានលក្ខណៈនាំមុខគឺមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់នៅក្នុងសវនាការចាប់តាំងពីការចាប់ផ្ដើម ។ ម៉្យាងវិញទៀត ការធ្វើសេចក្ដីសន្និដ្ឋានដោយភាគី ហើយស្នើដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សីឲ្យធ្វើការបញ្ជាក់ គឺត្រូវបានហាមឃាត់ជាដាច់ខាតនៅក្នុងនីតិវិធីដែលមានចែងក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡ ។ លោកចៅក្រមបានសង្កត់ធ្ងន់ទៀតថា អនុលោមតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានអនុម័តយល់ព្រមយកច្បាប់កម្ពុជាមកប្រើប្រាស់ជាអតិបរមានៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មេធាវីការពារក្ដីឲ្យជនជាប់ចោទ នួន ជា នៅតែពុំយល់ស្របនឹងការលើកឡើងរបស់ប្រធានអង្គជំនុំជម្រះ និងបានស្នើឲ្យអង្គជំនុំជម្រះបង្ហាញពីយុត្តិសាស្ត្រនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡណាមួយ ដែលហាមឃាត់ពុំឲ្យចោទសួរសំណួរនាំមុខចំពោះសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណី ។ បន្ថែមពីលើនេះ មេធាវី អ៊ីនូហ្វ៊ី ក៏បានលើកឡើងដែរថា សហព្រះរាជអាជ្ញា មេធាវីការពារក្ដីជនជាប់ចោទ អៀង សារី និង ចៅក្រមអង្គជំនុំជម្រះក៏ធ្លាប់បានប្រើប្រាស់សំណួរនាំមុខដើម្បីចោទសួរសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែរ ។ ទោះបីជាមេធាវីការពារក្ដីរូបនេះព្យាយាមលើកឡើងបន្ថែមក៏ដោយ ប្រធានអង្គជំនុំជម្រះបានបញ្ជាក់ជាចុងក្រោយថា អង្គជំនុំនឹងមិនអនុញ្ញាតឲ្យមានការចោទសួរសំណួរដែលមានលក្ខណៈនាំមុខនៅចំពោះមុខអង្គជំនុំជម្រះឡើយ ។

**គួរកត់សម្គាល់ថា** ប្រព័ន្ធច្បាប់ក្នុងប្រទេសកម្ពុជាត្រូវបានកំណត់យកតាមប្រព័ន្ធប្បវេណី និងកំពុងត្រូវបានអនុវត្ត ។ ប៉ុន្ដែអ្វីដែលគួរឲ្យចាប់អារម្មណ៍គឺ អង្គជំនុំជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាពេលបច្ចុប្បន្ន កំពុងដំណើរការនីតិវិធីរបស់ខ្លួនដោយមានការចូលរួមពីសំណាក់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ឬអ្នកច្បាប់ ដែលចេញមកពីប្រទេសដែលប្រកាន់យកប្រព័ន្ធច្បាប់ផ្សេងគ្នា ។ មានន័យថា តុលាការមួយប្រព័ន្ធច្បាប់ពីរ គឺអនុវត្តប្រព័ន្ធច្បាប់ប្បវេណីផង និងប្រព័ន្ធច្បាប់សាមញ្ញផង ។ ការណ៍នេះបានធ្វើឲ្យកិច្ចដំណើរការនីតិវិធីពេលខ្លះជួបប្រទះនឹងបញ្ហានៅក្នុងការអនុវត្ត ដូចជាអ្វីដែលកំពុងកើតមាននៅក្នុងនីតិវិធីនៃការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសវនាការថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ ។